ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ
Ministry of Agriculture,
Forestry and Fisheries

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

លេខៈ ២៩៧ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការជ្រើសរើសគ្រូបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ មិនា ឆ្នាំ ២០០១ ស្តីពីការបង្កើត និង គ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### សំរេច

<u>ប្រការ ១</u> : គ្រូបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកបច្ចេកទេសទាំងពីរភេទ ដែលត្រូវមានលក្ខណៈសម្បត្តិ :-

១- មានសញ្ជាតិខ្មែរ

២- មានសញ្ញាប័ត្រទាបបំផុតចាប់ពីមធ្យមបច្ចេកទេសផលិតកម្ម - បសុព្យាបាល ក្នុង ឬ ក្រៅប្រទេស ដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

៣- ត្រូវមានបទពិសោធន៍ ក្នុងមុខវិជ្ជាជីវៈរបស់ខ្លួន យ៉ាងតិចបីឆ្នាំ

ប្រការ ២ : នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ត្រូវបង្កើតគណៈកម្មការដើម្បីត្រួតពិនិត្យ និង វាយតម្លៃលើ សមត្ថភាពគ្រូបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ និង ចេញលិខិតទទួលស្គាល់ជាផ្លូវការ ។

ប្រការ ៣ : អគ្គនាយក អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋាន ផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត-ក្រុង ត្រូវអនុវត្តតាមប្រកាស នេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី 06 ខែ 7 ឆ្នាំ ២០០១

រដ្ឋមន្ត្រី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

ដើម្បីជូនជ្រាប

- ដូចប្រការ ៣

ដើម្បីអនុវត្ត

- ឯកសារ-កាលប្បវត្តិ